លីកាដូ

# សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

# LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

LICADHO

Mailing Address: P.O. Box 499
Phnom Penh, Cambodia
Main Office: #16, Street 99
Khan Chamkar Morn, Phnom Penh
Fax: (855) 23 360 965/217 626
Website: http://www.licadho.org/
E-mail: contact@licadho.org

## សេចក្តីប្រកាសព័ត៌មាន

## ការប្រើអំពើហិង្សាទៅលើសមាជិកសហជីព

អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ សូមធ្វើការថ្កោលទោសចំពោះអាជ្ញាធរដែលបានប្រើអំពើហិង្សាបង្ក្រាបកម្មករ ដែលចូលរួមធ្វើកូដកម្មនៅក្រៅរោងចក្រកាត់ដេរភ្នំពេញ កាលពីម្សិលមិញ ។

សមាជិកយ៉ាងតិចចំនួន ១០នាក់ នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានរងរបួសនៅក្នុងអំពើហិង្សានោះ ។ សមាជិកចំនួន ៨នាក់ បានប៉ះនឹងរថយន្តដែលបើកយ៉ាងលឿនចេញពីរោងចក្រ និងអ្នកឯទៀតត្រូវនគរបាល និងកងរាជអាវុធហត្ថវាយ ។

នៅថ្ងៃទី១១ ខែមករា សមាជិកប្រមាណជាង ៧០០នាក់ នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា នៅរោងចក្រកាត់ដេរ យីង ឡៃន ក្នុងស្រុកមានជ័យ បាននាំគ្នាធ្វើកូដកម្ម ។ ពួកគេបានទាមទារអោយទទួលយកអ្នកតំណាងសហជីពទាំង ១៩នាក់ ដែលរោងចក្របានបណ្តេញចេញកាលពីខែមិថុនា ២០០៧ ចូលធ្វើការវិញ និងអោយគណៈគ្រប់គ្រងរោងចក្ររក្សាពាក្យសន្យារបស់ខ្លួនពីមុន ដើម្បីជាការគោរពសិទ្ធិការងារ ។ ទោះជាយ៉ាងនេះក្តី ម្ចាស់រោងចក្រមិនបានធ្វើការចរចាណាមួយជាមួយអ្នកធ្វើកូដកម្មឡើយ ។

នៅថ្ងៃទី៦ ខែកុម្ភៈ ម្សិលមិញ ម៉ោងប្រហែល ៣រសៀល សមាជិកសហជីពប្រមាណ ៥០០នាក់ បានជួបជុំគ្នានៅខាងមុខរោងចក្រ ដោយបញ្ជាក់ថា គណៈគ្រប់គ្រងរោងចក្រមិនទាន់បានបើកប្រាក់បៀវត្សរ៍អោយពួកគេនៅឡើយតាំងពីមុនរហូតមកដល់ថ្ងៃទី១១ ខែមករា ជាថ្ងៃចាប់ផ្តើមធ្វើកូដកម្ម ។ កម្មករដទៃទៀតក្នុងរោងចក្របានបើកប្រាក់បៀវត្សរ៍រួចហើយ ។

ដោយមិនសប្បាយចិត្តនឹងម្ចាស់រោងចក្រ ឬអ្នកគ្រប់គ្រង ដែលមិនព្រមជួបជាមួយពួកគេ អ្នកធ្វើកូដកម្មទាំងនោះក៏បាននាំគ្នាសំដៅច្រកចូលរោងចក្រ ដើម្បីបិទកុំអោយរថយន្តចេញរួច ក្នុងគោលបំណងបញ្ចុះបញ្ចូលម្ចាស់រោងចក្រឱ្យយល់ព្រមបើកប្រាក់បៀវត្សរ៍ដែលនៅជំពាក់អោយបានមុនពេលចូលឆ្នាំចិន ។

បន្តិចក្រោយមក មេឃុំចាក់អង្រែក្រោម ឈ្មោះ ជា សុខកៃ អមដំណើរដោយនគរបាល និងកងរាជអាវុធហត្ថ ២៥នាក់ បានទៅដល់រោងចក្រ និងបញ្ជាអោយសមាជិកសហជីពចាកចេញពីច្រកចូលរោងចក្រ ។ នៅខណៈដែលកម្មករមិនព្រមចាកចេញ ជា សុខកៃ បានធ្វើកាយវិការបញ្ជាអោយរថយន្តពីរគ្រឿងបើកចេញពីរោងចក្រ ក្នុងពេលដែលកំលាំងនគរបាល និងកំលាំងកងរាជអាវុធហត្ថត្រូវបានគេបញ្ជាអោយចាំទប់ច្រានកម្មករថយក្រោយវិញ ។

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

Mailing Address: P.O. Box 499
Phnom Penh, Cambodia
Main Office: #16, Street 99
Khan Chamkar Morn, Phnom Penh
Fax: (855) 23 360 965/217 626
Website: http://www.licadho.org/
E-mail: contact@licadho.org

រថយន្តពីរគ្រឿងបានបើកចេញពីរោងចក្រយ៉ាងលឿន ដោយបានប៉ះកម្មករជាច្រើននាក់នៅតាមផ្លូវ ។ កម្មករស្ត្រីចំនួន ៤នាក់ អាយុពី១៨-២៥ឆ្នាំ រងរបួសជើង ឬដងខ្លួន ។ ចំនែកកម្មករចំនួន ៦នាក់ ផ្សេងទៀត រងរបួសដោយនគរបាល និងកងរាជអាវុធហត្ថវាយដោយដៃ និងដោយវិទ្យុទាក់ទង អាយកូម ។ កម្មកររងរបួសចំនួន ៥នាក់ នៃចំនួនអ្នករងរបួសទាំងអស់ បានចូលទៅព្យាបាលនៅគ្លីនិកមួយកន្លែង ។

អង្គការលីកាដូ សូមធ្វើការថ្កោលទោសចំពោះអាជ្ញាធរ ដែលបានប្រើហិង្សាហួសហេតុ ដោយគ្មានចេតនាណាមួយធ្វើការចរចាររកដំណោះស្រាយដោយសន្តិវិធី រវាងអ្នកធ្វើកូដកម្មនិងម្ចាស់រោងចក្រ ជាមុនសិនឡើយ ។ អង្គការលីកាដូ សូមស្នើអោយធ្វើការស៊ើបអង្កេត និងដាក់ទណ្ឌកម្មចំពោះអ្នកទទួលខុសត្រូវក្នុងការធ្វើអោយកម្មកររងរបួស ។

ហេតុការណ៏នេះ គឺជាផ្នែកមួយនៃគំរូអំពើហិង្សាដែលមានជាយូរយារមកហើយ សំរាប់ប្រើប្រឆាំងអ្នកតំនាងនិងសមាជិករបស់សហជីពនៅរោងចក្រកាត់ដេរ កាលពីប៉ុន្មានឆ្នាំថ្មីៗនេះ ដែលទង្វើទាំងនេះសរបញ្ជាក់អោយឃើញច្បាស់ថា ការការពារសិទ្ធិការងារនៅប្រទេសកម្ពុជាមានករិតយ៉ាប់យឺនខ្លាំងនៅឡើយ ។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងមន្ត្រីនានារបស់រដ្ឋាភិបាល បានបញ្ជាក់ដដែលៗថា វិស័យកាត់ដេរ ជាកត្តាសំខាន់ស្លាប់រស់នៃសេដ្ឋកិច្ចកម្ពុជា ។ វាផ្តល់ផលប្រយោជន៏ដល់ប្រជាជនកម្ពុជាគ្រប់ៗគ្នា និងដល់រាជរដ្ឋាភិបាលកម្ពុជា ដែលរាជរដ្ឋាភិបាលត្រូវប្តេជ្ញាចិត្តខ្ពស់ក្នុងការការពារសិទ្ធិការងារ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ដទៃទៀតរបស់កម្ពុជា ។

ព័តិមានបន្ថែម សូមទំនាក់ទំនង:

លោកស្រីវេជ្ជ.បណ្ឌិត **ពុង ឈីវកេក** ប្រធានអង្គការលីកាដូ ០១២ ៩៤០ ៦៤៥

លោក **អំ សំអាត** អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត អង្គការលីកាដូ ០១២ ៣២៧ ៧៧០